UNITED NATIONS
CAMBODIA

# សេចក្តីជូនដំណឹងដល់អ្នកសារព័ត៌មាន

**ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២២**

| | |
|---|---|
| ព្រឹត្តិការណ៍៖ | អគ្គលេខាធិការអង្គការសហប្រជាជាតិ លោក Antonio Guterres នឹងធ្វើទស្សនកិច្ចទៅកាន់សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង អំឡុងពេលចូលរួមកិច្ចប្រជុំកំពូល អាស៊ាន និងអង្គការសហប្រជាជាតិលើកទី១២ និងព្រឹត្តិការណ៍ពាក់ព័ន្ធនានានៅរាជធានីភ្នំពេញ។ |
| កាលបរិច្ឆេទ៖ | ថ្ងៃអាទិត្យ ទី១៣ ខែវិច្ឆិកា ឆ្នាំ២០២២ វេលាម៉ោង១២:៥៥ ដល់ ១៣:១០ រសៀល |
| ទីកន្លែង៖ | សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង |

លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ (UNSG) និងគណៈប្រតិភូនឹងចូលរួមក្នុងកិច្ចប្រជុំអាស៊ាន និងអង្គការសហប្រជាជាតិលើកទី១២ និងព្រឹត្តិការណ៍ពាក់ព័ន្ធនានានៅទីក្រុងភ្នំពេញ ចាប់ពីថ្ងៃទី១១ ដល់ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២២។ ក្នុងដំណើរទស្សនកិច្ចនេះ លោកអគ្គលេខាធិការ ក៏នឹងធ្វើទស្សនកិច្ចទៅកាន់សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែងផងដែរ។

ការិយាល័យអ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា សូមអញ្ជើញអ្នកសារព័ត៌មានជាតិ និងអន្តរជាតិ ចូលរួមពិធីថ្លែងសុន្ទរកថារបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ជាមួយអ្នកសារព័ត៌មាន បន្ទាប់ពីលោកបញ្ចប់ទស្សនកិច្ចនៅ សារមន្ទីរនេះ។ សុន្ទរកថារបស់ លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ Antonio Guterres នឹងធ្វើឡើងនៅបរិវេណសារមន្ទីរផ្ទាល់។

សម្រាប់ព័ត៌មានបន្ថែម និងបញ្ជាក់ការចូលរួម សូមទាក់ទងទៅកាន់កញ្ញា កែវ ស្រីស្រស់ មន្ត្រីទំនាក់ទំនងកម្មវិធី និងតស៊ូមតិ នៃការិយាល័យអ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា តាមរយៈ sreysros.keo@un.org ឬ (+855) 11 88 57 66។